ច្បាប់រដ្ឋ ម៉ាស្សាជូសេត្ទេស ស្តីពីម៉ោង និងប្រាក់ឈ្នួល

ប្រាក់ឈ្នួលអប្បបរមាគឺ 11.00ដុល្លារ

លេខទូរស័ព្ទរបស់ផ្នែកការងារស្មើភាព
(617) 727-3465 | TTY (617) 727-4765
ទូរស័ព្ទ៖ ពីម៉ោង10ព្រឹក ដល់ម៉ោង4ល្ងាច

www.mass.gov/ago/fairlabor
www.massworkrights.com

ការិយាល័យអគ្គព្រះរាជអាជ្ញា Maura Healey នៃរដ្ឋ ម៉ាស្សាជូសេត្ទេស

ប្រាក់ឈ្នួលអប្បបរមា
M.G.L. ជំពូក 151, កថាខណ្ឌ 1, 2, 2A, និង 7

ប្រាក់ឈ្នួលអប្បបរមាគឺ 11.00ដុល្លារ

នៅរដ្ឋ ម៉ាស្សាជូសេត្ទេស កម្មករទាំងអស់ត្រូវបានគេសន្មតទុកជាមុនថាជា និយោជិត។ និយោជិតទាំងអស់ ទទួលបានប្រាក់ឈ្នួលអប្បបរមានេះ លើកលែងតែ៖
- កម្មករក្នុងវិស័យកសិកម្ម (8.00 ដុល្លារក្នុងមួយម៉ោង គឺជាប្រាក់ឈ្នួលអប្បបរមារបស់កម្មករក្នុងវិស័យកសិកម្ម)
- សមាជិកក្រុមសាសនា
- កម្មករដែលកំពុងតែទទួលការបណ្តុះបណ្តាលក្នុងវិស័យអប់រំ អង្គការមិនយកប្រាក់កម្រៃ ឬអង្គការសាសនាណាមួយ និង
- អ្នកលក់ខាងក្រៅ។.

ការងារក្រៅម៉ោង
M.G.L. ជំពូក 151, កថាខណ្ឌ 1A និង 1B

ជាទូទៅ និយោជិតដែលធ្វើការលើស 40ម៉ោង ក្នុងមួយសប្តាហ៍ ត្រូវទទួលបានប្រាក់ក្រៅម៉ោង។ ប្រាក់ក្រៅម៉ោងយ៉ាងតិចណាស់មានចំនួន 1.5 ដងនៃអត្រាប្រាក់ឈ្នួលធម្មតាក្នុងមួយម៉ោង ប្រសិនបើនិយោជិតធ្វើការលើស 40ម៉ោងក្នុងមួយសប្តាហ៍។

សម្រាប់និយោជិតខ្លះដែលទទួលបាន "អត្រាកម្រៃសេវា" អត្រាប្រាក់ឈ្នួលក្រៅម៉ោងមានចំនួន 1.5 ដងនៃប្រាក់ឈ្នួលអប្បបរិមាគាល មិនមែននៃអត្រាប្រាក់សេវានោះទេ។

ករណីលើកលែង៖ តាមច្បាប់រដ្ឋ ការងារ និងកន្លែងការងារខ្លះត្រូវបានលើកលែងចេញពីការងារក្រៅម៉ោង ។ តារាងករណីលើកលែងលម្អិតអាចរកបានក្នុងគេហទំព័រ www.mass.gov/ago/fairlabor ឬទូរស័ព្ទមកផ្នែកការងារស្មើភាពរបស់អគ្គព្រះរាជអាជ្ញាតាមរយៈលេខ (617) 727-3465 ។

ការបង់ប្រាក់ឈ្នួល
M.G.L. ជំពូក149, កថាខណ្ឌ148; 454 C.M.R. 27.02

ក្នុងច្បាប់មានចែងថាតើនិយោជិតត្រូវទទួលបានប្រាក់ឈ្នួលនៅពេលណា តាមវិធីណា និងទទួលបានអ្វីខ្លះ។ ប្រាក់បៀវត្សរ៍របស់និយោជិត (ឬប្រាក់ឈ្នួល) រួមមានប្រាក់បៀវត្សរ៍នៃម៉ោងទាំងអស់ដែលពួកគេបានធ្វើការ បូករួមទាំងប្រាក់ទឹកតែ ប្រាក់បៀវត្សរ៍សម្រាប់ពេលឈប់សម្រាក ប្រាក់បៀវត្សរ៍សម្រាប់ពេលឈប់សម្រាកដែលគេបានសន្យា និងប្រាក់កម្រជើងសារដែលត្រូវបានកំណត់ច្បាស់លាស់ សមគួរ ហើយអាចបង់ថ្លៃបាន។

និយោជិតដែលទទួលបានប្រាក់បៀវត្សរ៍តាមចំនួនម៉ោងធ្វើការ ត្រូវទទួលបានប្រាក់បៀវត្សរ៍រៀងរាល់សប្តាហ៍ ឬពីរសប្តាហ៍ម្តង (ពីរសប្តាហ៍ម្តង)។

ថ្ងៃកំណត់បើកប្រាក់បៀវត្សរ៍ គឺ 6 ឬ 7 ថ្ងៃ បន្ទាប់ពីរយៈពេលទូទាត់ប្រាក់បៀវត្សរ៍ចប់ អាស្រ័យថាតើនិយោជិតធ្វើការប៉ុន្មានថ្ងៃក្នុងមួយសប្តាហ៍ក្នុងប្រតិទិន។

និយោជិតដែលលាឈប់ពីការងារ ត្រូវទទួលប្រាក់បៀវត្សរ៍ពេញលេញ នៅថ្ងៃបើកប្រាក់បៀវត្សរ៍បន្ទាប់ ឬត្រឹមថ្ងៃសៅរ៍បន្ទាប់ពីពួកគេលាឈប់ (ប្រសិនបើគ្មានថ្ងៃបើកប្រាក់បៀវត្សរ៍ទៀងទាត់)។ និយោជិតដែលត្រូវបានបណ្តេញចេញ ឬបញ្ឈប់ពីការងារ ត្រូវទទួលប្រាក់បៀវត្សរ៍ពេញលេញ នៅថ្ងៃធ្វើការចុងក្រោយរបស់ពួកគេ។

ប្រាក់ទឹកតែ
M.G.L. ជំពូក 149, កថាខណ្ឌ 152A; M.G.L. ជំពូក 151, កថាខណ្ឌ 7

និយោជិតដែលផ្តល់សេវាកម្មអោយអតិថិជន និងនិយោជិតដែលរកបានប្រាក់ទឹកតែលើសពី 20 ដុល្លារក្នុងមួយខែ អាចទទួល "អត្រាកម្រៃសេវា" តាមចំនួនម៉ោងធ្វើការ។

អត្រាកម្រៃសេវា គឺ **3.75** ដុល្លារក្នុងមួយម៉ោង។ ប្រាក់ទឹកតែតាមចំនួនម៉ោងធ្វើការជាមធ្យម រួមនិងអត្រាកម្រៃសេវាតាមចំនួនម៉ោងធ្វើការ ត្រូវបង់អោយកម្មករបន្ថែមរហូតដល់ចំនួន 11.00 ដុល្លារ (ឬច្រើនជាងនេះ)។

អ្នកគ្រប់គ្រង អ្នកមើលខុសត្រូវ និងម្ចាស់ មិនត្រូវយកចំណែកណាមួយនៃប្រាក់ទឹកតែរបស់និយោជិតរបស់ខ្លួនឡើយ។

ប្រាក់ទឹកតែ និងតម្លៃសេវាក្នុងវិក្កយប័ត្រ ត្រូវផ្តល់អោយអ្នកបម្រើ អ្នកចាក់ស្រា ឬនិយោជិតបម្រើផ្សេងទៀតតែប៉ុណ្ណោះ ទៅតាមសេវាកម្មដែលនិយោជិតម្នាក់ៗផ្តល់អោយ។

ការចែកប្រាក់ទឹកតែរួមត្រូវបានអនុញ្ញាតអោយអ្នកបម្រើ អ្នកចាក់ស្រានិងនិយោជិតបម្រើផ្សេងៗតែប៉ុណ្ណោះ។

ព័ត៌មានស្តីពីរបាយការណ៍ប្រាក់បៀវត្សរ៍
M.G.L. ជំពូក 149, កថាខណ្ឌ 148

និយោជិតទាំងអស់ត្រូវទទួលរបាយការណ៍មួយជាមួយនឹងប្រាក់បៀវត្សរ៍របស់ពួកគេ ដោយមិនគិតថ្លៃ ដែលក្នុងរបាយការណ៍នោះមានឈ្មោះនិយោជក ឈ្មោះនិយោជិត ថ្ងៃបើកប្រាក់បៀវត្សរ៍ (ខែ ថ្ងៃ និងឆ្នាំ) ចំនួនម៉ោងដែលពួកគេបានធ្វើការក្នុងរយៈពេលទូទាត់ប្រាក់បៀវត្សរ៍ អត្រាកម្រៃក្នុងមួយម៉ោង និងការកាត់ប្រាក់កម្រៃ ឬបន្ថែមប្រាក់កម្រៃទាំងអស់ក្នុងរយៈពេលទូទាត់ប្រាក់បៀវត្សរ៍។

ការកាត់ប្រាក់បៀវត្សរ៍
M.G.L. ជំពូក 149, កថាខណ្ឌ 148; 454 C.M.R. 27.05

និយោជកមិនអាចកាត់ប្រាក់បៀវត្សរ៍របស់និយោជិតបានទេ លុះត្រាតែច្បាប់អនុញ្ញាតអោយកាត់ (ដូចជា ពន្ធធរដ្ឋបនិងពន្ធសហព័ន្ធ លើប្រាក់ចំណូល) ឬលុះត្រាតែនិយោជិតបានសុំឲ្យកាត់ប្រាក់បៀវត្សរ៍ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គាត់ (ដូចជា ទុកប្រាក់ក្នុងគណនីសន្សំរបស់និយោជិត)។

និយោជកមិនអាចដកប្រាក់ពីប្រាក់បៀវត្សរ៍របស់និយោជិត ទៅចេញថ្លៃចំណាយអាជីវកម្មទូទៅរបស់និយោជកបានទេ (ដូចជា ការផ្គត់ផ្គង់សម្ភារៈ ឬឧបករណ៍ចាំបាច់ដែលនិយោជិតត្រូវការដើម្បីបំពេញការងារ)។ និយោជកដែលទាមទារអោយនិយោជិតទិញ ឬជួលឯកសណ្ឋាន ត្រូវចេញសងប្រាក់ទាំងអស់នោះវិញ អោយទៅនិយោជិត។

ច្បាប់ក៏ដាក់កម្រិតផងដែរថានៅពេលណា និងចំនួនទឹកប្រាក់ប៉ុន្មានដែលនិយោជកអាចដកពីប្រាក់បៀវត្សរ៍របស់និយោជិត ចំពោះការចំណាយលើកន្លែងស្នាក់នៅ និងអាហារដែលនិយោជកផ្តល់ឲ្យនិយោជិត។

ម៉ោងដែលបានធ្វើការ
454 C.M.R. 27.02

ម៉ោងដែលបានធ្វើការ ឬ "ម៉ោងធ្វើការ" រួមមានពេលវេលាទាំងអស់ដែលនិយោជិតត្រូវបំពេញភារកិច្ចនៅកន្លែងការងាររបស់និយោជក ឬនៅទីតាំងផ្សេងទៀត និងធ្វើការមុនឬក្រោយម៉ោងធ្វើការធម្មតាដើម្បីបញ្ចប់កិច្ចការ។.

ពេលសម្រាកបរិភោគអាហារ
M.G.L. ជំពូក 149, កថាខណ្ឌ 100 និង 101

និយោជិតភាគច្រើនដែលធ្វើការលើសពី 6 ម៉ោង ត្រូវមានពេលសម្រាកបរិភោគអាហាររយៈពេល 30 នាទី។ ក្នុងអំឡុងពេលសម្រាកបរិភោគអាហារ និយោជិតត្រូវមានពេលទំនេរពីការងារ និងមានសិទ្ធចេញពីកន្លែងការងារ។ ប្រសិនបើនិយោជកស្នើសុំអោយនិយោជិតធ្វើការ ឬមិនចាកចេញពីកន្លែងការងារក្នុងអំឡុងពេលសម្រាកបរិភោគអាហារ ហើយនិយោជិតយល់ព្រម នោះនិយោជិតត្រូវទទួលប្រាក់កម្រៃសម្រាប់ពេលវេលានោះ។

កំណត់ត្រាបញ្ជីប្រាក់បៀវត្សរ៍
M.G.L. ជំពូក 151, កថាខណ្ឌ 15

កំណត់ត្រាបញ្ជីប្រាក់បៀវត្សរ៍ត្រូវមានឈ្មោះ អាសយដ្ឋាន ការងារ/មុខរបរ ចំនួនប្រាក់បៀវត្សរ៍ ទទួលបានក្នុងរយៈពេលទូទាត់ និងចំនួនម៉ោងបានធ្វើការ (រៀងរាល់ថ្ងៃ និងសប្តាហ៍) របស់និយោជិត។

និយោជកត្រូវរក្សាទុកកំណត់ត្រាបញ្ជីប្រាក់បៀវត្សរ៍រយៈពេល 3 ឆ្នាំ។ និយោជិតមានសិទ្ធិមើលកំណត់ត្រាបញ្ជីប្រាក់បៀវត្សរ៍របស់ខ្លួន នៅពេល និងទីកន្លែងសមគួរ។

សចេក្តីជូនដំណឹងនៅកន្លែងការងារ៖ ច្បាប់រដ្ឋតម្រូវអោយនិយោជកទាំងអស់បិទប្រកាសសចេក្តីជូនដំណឹងនេះនៅកន្លែងការងារ ក្នុងទីតាំងមួយដែលងាយមើលឃើញ។
M.G.L. ជំពូក 151, កថាខណ្ឌ 16; 454 C.M.R. 27.01(1)

ពេលឈប់សម្រាកឈឺ
M.G.L. ជំពូក 149, កថាខណ្ឌ 148C

និយោជិតភាគច្រើនមានសិទ្ធិទទួលបានពេលឈប់សម្រាកឈឺរយៈពេល 1 ម៉ោងរៀងរាល់ 30 ម៉ោង ដែលពួកគេធ្វើការ ហើយពួកគេអាចទទួលបានពេលឈប់សម្រាកឈឺរហូតដល់ 40 ម៉ោងក្នុងមួយឆ្នាំ។ និយោជិតចាប់ផ្តើមរាប់ពេលឈប់សម្រាកឈឺ នៅថ្ងៃដំបូងដែលពួកគេចាប់ផ្តើមធ្វើការ។ និយោជិតត្រូវមានសិទ្ធយកពេលឈប់សម្រាកឈឺ បន្ទាប់ពីធ្វើការបាន 90 ថ្ងៃ។

និយោជិតដែលលក្ខខណៈសម្បត្តិ អាចប្រើពេលឈប់សម្រាកឈឺរបស់ពួកគេ ប្រសិនបើពួកគេផ្ទាល់ កូន ប្តីឬប្រពន្ធ ឪពុកម្តាយ ឬឪពុកម្តាយរបស់ប្តីឬប្រពន្ធឈឺ របួស ឬមានការណាត់ជួបគ្រូពេទ្យជាប្រចាំ។ ពួកគេក៏អាចប្រើប្រាស់ពេលឈប់សម្រាកឈឺសម្រាប់ខ្លួនគេ ឬសម្រាប់កូនរបស់ពួកគេ ដើម្បីដោះស្រាយផលនៃអំពើហិង្សាក្នុងគ្រួសារផងដែរ ។និយោជិតត្រូវជូនដំណឹងដល់និយោជកមុនពេលប្រើប្រាស់ពេលវេលាឈប់សម្រាកឈឺ លើកលែងតែក្នុងស្ថានភាពបន្ទាន់។

និយោជិតដែលមិនបានមកធ្វើការលើសពី 3 ថ្ងៃជាប់គ្នា អាចនឹងចាំបាច់ត្រូវផ្តល់កំណត់ហេតុពីវេជ្ជបណ្ឌិតឲ្យទៅនិយោជករបស់ខ្លួន។

ពេលឈប់សម្រាកឈឺដែលនៅតែទទួលប្រាក់បៀវត្សរ៍

និយោជកដែលមាននិយោជិត 11នាក់ ឬច្រើនជាងនេះ ត្រូវផ្តល់ពេលឈប់សម្រាកឈឺដែលនិយោជិតនៅតែទទួលបានប្រាក់បៀវត្សរ៍។ និយោជកដែលមាននិយោជិតតិចជាង 11 នាក់ ត្រូវផ្តល់ពេលឈប់សម្រាកឈឺ ប៉ុន្តែមិនចាំបាច់ផ្តល់ប្រាក់បៀវត្សរ៍អោយនិយោជកក្នុងអំឡុងពេលនោះទេ។ សូមស្វែងយល់បន្ថែមអំពីពេលឈប់សម្រាកឈឺក្នុងគេហទំព័រ *www.mass.gov/ago/earnedsicktime* ។

និយោជកមិនត្រូវរើសអើង
M.G.L. ជំពូក 149, កថាខណ្ឌ 105A; M.G.L. ជំពូក 151B, កថាខណ្ឌ 4

អាស្រ័យតាមករណីលើកលែងមួយចំនួន និយោជកមិនត្រូវបង់ប្រាក់បៀវត្ស៍អោយនិយោជិតណាម្នាក់តិចជាងនិយោជិតមួយទៀតដែលមានភេទខុសគ្នា សម្រាប់កិច្ចការដូចគ្នា ឬកិច្ចការប្រហាក់ប្រហែលគ្នានោះទេ។

ពួកគេមិនត្រូវមានភាពរើសអើសក្នុងការជ្រើសរើសបុគ្គលិក ការបង់ប្រាក់បៀវត្សរ៍ ឬសំណងផ្សេងៗ ឬលក្ខខណ្ឌការងារផ្សេងៗផ្អែកលើលក្ខណៈមនុស្សដូចខាងក្រោមទេ៖
- ពូជសាសន៍ ឬពណ៌សម្បុរ
- សាសនា ដើមកំណើតប្រទេស ឬពូជពង្ស
- ភេទ (រួមទាំងមានផ្ទៃពោះ)
- កាតព្វកិច្ចយោធា
- ទំនាក់ផ្លូវភេទ ឬអត្តសញ្ញាណភេទ ឬការបង្ហាញភេទ
- ព័ត៌មានស្តីពីពូជ ឬពិការភាព
- អាយុ

ការឈប់សម្រាកចាំបាច់តិចតួច
M.G.L. ជំពូក 149, កថាខណ្ឌ 52D

ក្នុងករណីខ្លះ និយោជិតមានសិទ្ធិឈប់សម្រាកគ្មានប្រាក់បៀវត្សរ៍រហូតដល់ 24 ម៉ោង រៀងរាល់ 12 ខែ សម្រាប់៖
- កម្មវិធីនៅសាលារៀនរបស់កូន
- ការណាត់ជួបវេជ្ជបណ្ឌិត ឬទន្តពេទ្យរបស់កូន ឬ
- ការណាត់ជួបវេជ្ជបណ្ឌិត ឬទន្តពេទ្យរបស់សមាជិកគ្រួសារដែលមានវ័យចាស់ ឬការណាត់ជួបផ្សេងៗ

យោជិតមានសិទ្ធឈប់សម្រាកបបែនេះ ប្រសិនបើនិយោជកមាននិយោជិតយ៉ាងតិច 50 នាក់ ហើយជានិយោជិតដែល៖
- បានធ្វើការយ៉ាងតិចណាស់ 12 ខែ អោយនិយោជកនោះ និង
- បានធ្វើការយ៉ាងតិចណាស់ 1,250 ម៉ោង អោយនិយោជកនោះក្នុងរយៈពេល 12 ខែកន្លងមក។

របាយការណ៍ប្រាក់បៀវត្សរ៍
454 C.M.R. 27.04

និយោជិតភាគច្រើនត្រូវបានប្រាក់បៀវត្សរ៍ 3 ម៉ោង ដែលមិនតិចជាងប្រាក់ឈ្នួលអប្បបរមា ប្រសិនបើគាត់ ត្រូវបានគេកំណត់ពេលឲ្យធ្វើការរយៈពេល 3 ម៉ោង ឬច្រើនជាងនេះ ហើយទៅធ្វើការទាន់ពេលវេលា ហើយមិនបានទទួលចំនួនម៉ោងការងារដូចការរំពឹងទុក។

សិទ្ធរបស់កម្មករបណ្តោះអាសន្ន
M.G.L. ជំពូក 149, កថាខណ្ឌ 159C

ដើម្បីស្វែងយល់ពីសិទ្ធរបស់កម្មករបណ្តោះអាសន្ន និងនិយោជិតដែលជ្រើសរើសអោយធ្វើការតាមរយៈទីភ្នាក់ងាររកមនុស្សធ្វើការ សូមទូរស័ព្ទមក 617-626-6970 ឬចូលទៅកាន់ *www.mass.gov/dols/* ។

សិទ្ធិរបស់កម្មករក្នុងស្រុក
M.G.L. ជំពូក 149, កថាខណ្ឌ 190

ដើម្បីស្វែងយល់ពីសិទ្ធិបន្ថែមសម្រាប់កម្មករថែរក្សាផ្ទះ សម្អាត ថៃទាំកុមារ ចម្អិនអាហារ គ្រប់គ្រងគេហដ្ឋាន ថៃទាំចាស់ជរា ឬសេវាប្រហាក់ប្រហែលនេះក្នុងក្រុមគ្រួសារ សូមចូលទៅ *www.mass.gov/ago/DW* ។

ការងារសាធារណៈ និងកម្មករសំណង់សាធារណៈ
M.G.L. ជំពូក 149, កថាខណ្ឌ 26-27H

កម្មករដែលធ្វើការក្នុងគម្រោងសាងសង់សាធារណៈ និងការងារសាធារណៈផ្សេងៗណាមួយត្រូវទទួលប្រាក់ឈ្នួលទូទៅគឺអត្រាប្រាក់អប្បបរមាដែលកំណត់ដោយនាយកដ្ឋានស្តង់ដារការងារ (Department of Labor Standards) ផ្អែកលើប្រភេទការងារដែលពួកគេបំពេញ។

ការសម្រាកដោយសារអំពើហិង្សាក្នុងគ្រួសារ
M.G.L. ជំពូក 149, កថាខណ្ឌ 52E

និយោជិតដែលជាជនរងគ្រោះ ឬសមាជិកគ្រួសាររបស់និយោជិតជាជនរងគ្រោះដោយសារតែអំពើហិង្សាក្នុងគ្រួសារ ការបំពានផ្លូវភេទ ការឈ្លបចាប់ ឬការចាប់ជំរិតមានសិទ្ធសម្រាករយៈពេល 15 ថ្ងៃ សម្រាប់តម្រូវការពាក់ព័ន្ធ ដូចជាការថៃទាំសុខភាព ប្រឹក្សាយោបល់ និងសេវាជនរងគ្រោះ សុវត្ថិភាពលំនៅដ្ឋាន ការថែរក្សានិងគ្រប់គ្រងកូនរបស់ពួកគេ ព្រមទាំងជំនួយផ្លូវច្បាប់ ច្បាប់ការពារ និងការទៅតុលាការ។

សម្រាប់ការឈប់សម្រាកនេះ និយោជិតអាចទទួលប្រាក់បៀវត្សរ៍ ឬគ្មានប្រាក់បៀវត្សរ៍ អាស្រ័យលើគោលនយោបាយរបស់និយោជក។ ច្បាប់នេះត្រូវយកមកអនុវត្តចំពោះនិយោជកណាដែលមាននិយោជិត 50 នាក់ ឬច្រើនជាងនេះ។

និយោជិតមានសិទ្ធប្តឹង

និយោជិតមានសិទ្ធប្តឹងនិយោជករបស់ខ្លួន ពីការរំលោភបំពានច្បាប់ស្តីពីប្រាក់ឈ្នួល និងម៉ោងធ្វើការ។ និយោជិតអាចប្តឹងក្នុងនាមជាបុគ្គល ឬពួកគេអាចប្តឹងនិយោជករបស់ខ្លួនក្នុងនាមជាក្រុម ប្រសិនបើពួកគេមានពាក្យបណ្តឹងប្រហាក់ប្រហែលគ្នា។ និយោជិតដែលឈ្នះ បណ្តឹងក្តីរបស់ខ្លួន នឹងទទួលបានមកវិញនូវប្រាក់បៀវត្សរ៍ ប្រាក់សំណងបីដង ថ្លៃសេវាមេធាវី និងថ្លៃតុលាការ។

ប្រការសំខាន់! ការចាប់ផ្តើមធ្វើពាក្យបណ្តឹងមានថ្ងៃផុតកំណត់ច្បាស់លាស់។ សម្រាប់រឿងក្តីភាគច្រើន ថ្ងៃផុតកំណត់គឺ រយៈពេល 3 ឆ្នាំបន្ទាប់ពីការរំលោភបំពានកើតឡើង។

និយោជកមិនត្រូវសងសឹក
M.G.L. ជំពូក 149, កថាខណ្ឌ 148A; M.G.L. ជំពូក 151, កថាខណ្ឌ 19

វាជាទង្វើខុសច្បាប់បើសិនជានិយោជកពិន័យ ឬរើសអើងនិយោជិតណាម្នាក់ ដោយសារតែពាក្យបណ្តឹង ឬដោយសារតែនិយោជិតព្យាយាមអនុវត្តសិទ្ធដែលត្រូវបានពន្យល់ក្នុងសចេក្តីប្រកាសនេះ។

ច្បាប់ដែលត្រូវបានពន្យល់ក្នុងសចេក្តីប្រកាសនេះ ត្រូវយកមកអនុវត្តចំពោះកម្មករទាំងអស់ ដោយពុំគិតពីឋានៈអន្តោប្រវេសន៍ រួមទាំងកម្មករគ្មានឯកសារការងារ។ ប្រសិនបើនិយោជកម្នាក់រាយការណ៍ ឬគំរាមកំហែងថានឹងរាយការណ៍ពីកម្មករណាម្នាក់ទៅអាជ្ញាធរអន្តោប្រវេសន៍ ពីព្រោះតែកម្មករនោះបានប្តឹងត៉ាអំពីការរំលោភសទ្ធិ និយោជកនោះអាចត្រូវបានកាត់ទោស និង/ឬត្រូវទទួលពិន័យស៊ីវិល។

និយោជិតដែលមានអាយុក្រោម 18 ឆ្នាំ-ពលកម្មកុមារ
M.G.L. ជំពូក 149, កថាខណ្ឌ 56 –105

និយោជកទាំងអស់នៅរដ្ឋ ម៉ាស្សាជូសេត្ទេស ត្រូវគោរពច្បាប់រដ្ឋ និងសហព័ន្ធ ចំពោះនិយោជិតដែលមានអាយុក្រោម 18 ឆ្នាំ (អនីតិជន)។ ច្បាប់ទាំងនេះចែងអំពី ពេលណា ទីកន្លែងណា និង រយៈពេលយូរប៉ុណ្ណា ដែលអនីតិជនអាចធ្វើការបាន។ ច្បាប់ទាំងនេះក៏ចែងពីប្រភេទការងារ ឬកិច្ចការដែលអនីតិជនមិនត្រូវធ្វើដែរ។

ទាមទារលិខិតអនុញ្ញាតការងារ -- កម្មករអាយុក្រោម 18ឆ្នាំ ភាគច្រើន ត្រូវតែមានលិខិតអនុញ្ញាតការងារ។ និយោជកត្រូវរក្សាទុកលិខិតអនុញ្ញាតការងាររបស់កម្មករជាអនីតិជន ក្នុងសំណុំឯកសារនៅកន្លែងការងារ។ ដើម្បីសុំលិខិតអនុញ្ញាតការងារ អនីតិជនត្រូវស្នើសុំអ្នកគ្រប់គ្រងកម្មវិធីសាលាដែលគាត់រស់នៅ ឬទៅរៀន។ សម្រាប់ព័ត៌មានបន្ថែមការសុំលិខិតអនុញ្ញាតការងារ សូមទាក់ទងនាយកដ្ឋានស្តង់ដារការងារ តាមរយៈលេខទូរស័ព្ទ (617) 626-6975 ឬគេហទំព័រ *www.mass.gov/dols* ។

កិច្ចការ & ការងារគ្រោះថ្នាក់ដែលអនីតិជនមិនត្រូវធ្វើ

អាយុ	មិនត្រូវ	
16 & 17	• បើកបរឡានស្ទូច ឬយានយន្តស្ទើរគ្រប់ប្រភេទ • ធ្វើអ្វីដែលតម្រូវអោយប្រើ ឬមានកាំភ្លើង • ប្រើប្រាស់ សម្អាត ឬជួសជុលប្រភេទម៉ាស៊ីនណាមួយដើរដោយថាមពល	• ចាត់ចែង ផ្តល់សេវា ឬលក់គ្រឿងស្រវឹង • ធ្វើការកំពស់ 30 ហ្វីតផុតពីដី ឬខ្ពស់ជាងនេះ
14 & 15	• ចម្អិន (លើកលែងតែចង្ក្រានអាំងដោយអគ្គិសនី ឬឧស្ម័នដែលគ្មានអណ្តាតភ្លើង) ប្រើខ្ទះឆា ប្រដាប់ខ្វៃសាច់ ឧបករណ៍ផ្ទះបាយ ប្រដាប់អាំងសាច់ NIECO ឬចង្ក្រានមានសម្ពាធ • ប្រើប្រាស់ សម្អាត ឬជួសជុលម៉ាស៊ីនកិនអាហារ ម៉ាស៊ីនកិន ម៉ាស៊ីនជញ្ជូចាំសាច់ ម៉ាស៊ីនចូនសៃច់ ម៉ាស៊ីនកាត់ និងម៉ាស៊ីនក្រឡុកដើរដោយថាមពល	• ធ្វើការក្នុងទូរទឹកកក ឬទូរដាក់សាច់ • ដុត • ធ្វើការក្នុង ឬជិតរោងចក្រ ការដ្ឋានសាងសង់ រោងចក្រផលិតកម្ម កន្លែងយានដ្ឋានប្រើម៉ាសិន ផ្លូវក្រោមដី ឬកន្លែងការងារមានហានិភ័យផ្សេងទៀត
Under 14	• អនីតិជនអាយុក្រោម 14 ឆ្នាំ មិនអាចធ្វើការបានទេក្នុងរដ្ឋ ម៉ាស្សាជូសេត្ទេស ក្នុងករណីភាគច្រើន	

ទាំងនេះគ្រាន់តែជាឧទាហរណ៍នៃកិច្ចការដែលត្រូវបានហាមប្រាមក្នុងច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ។ សម្រាប់តារាងលម្អិតនៃបម្រាមការងារសម្រាប់អនីតិជន សូមទាក់ទងផ្នែកការងារស្មើភាពរបស់អគ្គរាជអាជ្ញា៖ (617) 727-3465 • *www.mass.gov/ago/youthemployment.* ។ ឬទាក់ទងក្រសួងការងារសហរដ្ឋអាមេរិក៖ (617) 624-6700 • *www.youth.dol.gov*

ការកម្រិតពេលវេលា &តារាងពេលវេលា សម្រាប់អនីតិជន

អាយុ	មិនត្រូវធ្វើការ	នៅពេលណាមួយ៖
16 & 17	នៅ**ពេលយប់** ពីម៉ោង 10 ល្ងាច ដល់ 6 ព្រឹក (ឬហួសម៉ោង 10.15 ប្រសិនបើនិយោជកឈប់បម្រើអតិថិជននៅម៉ោង 10 យប់) លើកលែង ៖នៅយប់អត់រៀន អាចធ្វើការរហូតដល់ 11.30 យប់ ឬរហូតដល់ពាក់កណ្តាលយប់ ប្រសិនបើធ្វើការនៅភោជនីយដ្ឋាន ឬទីលានប្រណាំង។	• លើសពី **9 ម៉ោង** ក្នុងមួយថ្ងៃ • លើសពី **48 ម៉ោង** ក្នុងមួយសប្តាហ៍ • លើសពី **6 ថ្ងៃ** ក្នុងមួយសប្តាហ៍
14 & 15	នៅ**ពេលយប់** ពី 7 ល្ងាច ដល់ 7 ព្រឹក លើកលែង ៖ នៅរដូវក្តៅ (ថ្ងៃទី1 ខែកក្កដា--ទិវាពលកម្ម) អាចធ្វើការរហូតដល់ម៉ោង 9 យប់ **អំឡុងឆ្នាំសិក្សា៖*** • លើសពី **3ម៉ោង** នៅថ្ងៃសិក្សា • លើសពី **18ម៉ោង** ក្នុងអំឡុងសប្តាហ៍ • លើសពី **8ម៉ោង** នៅចុងសប្តាហ៍ ឬថ្ងៃសម្រាក	**ពេលមិនមានម៉ោងរៀន៖** • លើសពី **8 ម៉ោង** នៅថ្ងៃណាក៏ដោយ • លើសពី **40 ម៉ោង** ក្នុងមួយសប្តាហ៍ • លើសពី **6 ថ្ងៃ** ក្នុងមួយសប្តាហ៍

*លើកលែង៖ សម្រាប់អាជីពដែលមានការយល់ព្រមពីសាលា ឬការងាបង្កើនបទពិសោធន៍ សិស្សអាចត្រូវបានអនុញ្ញាតឲ្យធ្វើការក្នុងអំឡុងថ្ងៃសិក្សា រហូតដល់ 23ម៉ោងក្នុងមួយសប្តាហ៍។

ទាមទារការមើលការខុសត្រូវពីមនុស្សពេញវ័យ ចាប់ពីម៉ោង 8 ល្ងាច - ចាប់ពីម៉ោង 8 ល្ងាចទៅ មនុស្សពេញវ័យដែលមានវត្តមាននៅកន្លែងការងារហើយងាយស្រួលទាក់ទង ត្រូវមើលការខុសត្រូវលើអនីតិជនទាំងអស់។ លើកលែង៖ មិនចាំបាច់មានមនុស្សពេញវ័យមើលការខុសត្រូវលើអនីតិជនដែលធ្វើការនៅបញ្ជរ ឬតូបនៅបរិវេណធម្មតាក្នុងអាគារផ្សារទំនើបដែលមានសន្តិសុខចាប់ពីម៉ោង 8 យប់រហូតដល់ហាងបិទ។